ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៩៣៦ សហវ.ប្រក.

# ប្រកាស
## ស្តីពី
## ការកែសំរួលអត្រាពន្ធ និងអាករលើទំនិញមួយចំនួន (ស្រាបៀរ)

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃ ទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០

- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអាត្រាពន្ធ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអាត្រាពន្ធ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញប្រកាសលេខ ៣៤១ ប្រក/សហវ/ពដ ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- យោងស្មារតីនៃការប្រជុំនាថ្ងៃទី ១៩ និង ២០ វិច្ឆិកា ឆ្នាំ ២០០១ របស់គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៧

## សំរេច

**ប្រការ ១.**

ត្រូវបានកែប្រែ និងកំណត់អត្រាអាករពិសេស **២០ ភាគរយ** លើមុខទំនិញស្រាបៀរ ដែលមានទីតាំងរងលេខ ២២០៣.០០.១០ ២២០៣.០០.៩០ នៃតារាងពន្ធគយកម្ពុជា ជាធរមាន ។

**ប្រការ ២.**

យោងតាមផ្នែកទី ២.១ និង ២.២ នៃប្រកាស លេខ ៣៤១ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ១៩៩៧ ស្តីពីអាករពិសេសលើទំនិញនិងសេវាមួយចំនួន, អ្នកនាំចូល និងផលិតករក្នុងស្រុក ត្រូវមានកាតព្វកិច្ចបង់អាករពិសេសលើស្រាបៀរ ដូចខាងក្រោម:

១-ចំពោះអ្នកនាំចូល ត្រូវបង់អាករពិសេសលើស្រាបៀរនាំចូលដោយផ្អែកលើតំលៃក្នុងគយ បូកបន្ថែមពន្ធ និងអាករដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសលើខ្លួនឯង និងអាករលើតំលៃបន្ថែមដែលបានបង់នាពេលនាំចូល, នៅមុនពេលយកទំនិញចេញពីការឃុំគ្រងរបស់ទីចាត់ការគយ និងរដ្ឋាករ ។

២- ចំពោះផលិតករក្នុងស្រុក ត្រូវប្រមូលអាករពិសេសនៅពេលធ្វើការផ្គត់ផ្គង់ស្រាបៀរទាំងនោះ ដោយផ្អែកលើថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយបត្រ។

**ប្រការ ៣.**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០២ នេះតទៅ ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

**គាត ឈន់**

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង " ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីមុខងារ"
- គ្រប់អង្គភាពពន្ធដារ-ទីចាត់ការគយ និង រដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ